# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ករណីពិសេសរបស់អង្គុលីមាលដែលសម្លាប់មនុស្សយ៉ាងច្រើន តែមិនបានទទួលផលបាប ។

www.hoksavann,com

ថ្ងៃទី២២ វិច្ឆិកា ២០១០



រឿងអង្គុលីមាលក្នុងព្រះពុទ្ធសាសនា ជារឿងចម្លែកប្លែកពីរឿងនានា ដែលទាក់ទងទៅនឹងការសម្លាប់មនុស្សយ៉ាងច្រើន តែមិនបានទទួលផលបាប ។ រឿងអង្គុលីមាលសម្លាប់មនុស្សយ៉ាងច្រើន នៅតែម្នាក់ទៀតគ្រប់១០០០នាក់ ហើយមិនបានទទួលផលបាបនេះ លោកចាត់ទុកជាករណីពិសេស ហើយកម្រមានរបៀបនេះណាស់ ព្រោះអ្នកសាងបាបត្រូវតែទទួលផលបាបដាច់ខាតពុំអាចជៀសវាងបានឡើយ ។ ករណីរបស់អង្គុលីមាលនេះ ពុទ្ធសាសនាបានបញ្ជាក់ថា អង្គុលីមាលក្នុងបច្ចុប្បន្ននេះត្រូវបានសំរេចជាព្រះអរហត្ត ដែលជានិស្ស័យកសាងពីបុព្វជាតិ តែមានគំនិតទៅសម្លាប់មនុស្សនោះ ដោយការសេពគប់ខុស ពុំទាន់បានជួបលោកអ្នកសប្បុរសជួយណែនាំផ្លូវធម៌ ។ តាមដំណើររឿង នាមដើមរបស់អង្គុលីមាលឈ្មោះអហឹង្សកុមារ ដែលប្រែថាអ្នកពុំបៀតបៀនគេ រស់នៅក្នុងត្រកូលមួយជាមួយមាតា បានទៅសិក្សានិងបំរើអាចារ្យទិសាបាមោក្ខដោយគោរព ដែលធ្វើឲ្យអាចារ្យពេញចិត្តយ៉ាងខ្លាំង ។ ពេលនោះការច្រណែនក៏កើតមានក្នុងចំណោមសិស្សដែលរៀនជាមួយគ្នា ក៏រកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីកំចាត់អហឹង្សកុមារ ទើបទៅញុះញង់អាចារ្យឲ្យស្អប់អហឹង្សកុមារ ដោយនិយាយមួលបង្កាច់ដោយប្រការផ្សេងៗ ។ ដោយការញុះញង់ជាញឹកញាប់ និងអាចារ្យខ្វះការពិចារណាឲ្យដឹងការពិតផង លោកអាចារ្យក៏សំរេចចិត្តសម្លាប់អហឹង្សកុមារ ។ វិធីសម្លាប់ លោកអាចារ្យបានប្រើវិធីបញ្ឆោតអហឹង្សកុមារថា ចូរទៅសម្លាប់មនុស្សមានឋានៈបែបណាក៏ដោយឲ្យគ្រប់ចំនួន១០០០ មកផ្សំធ្វើជាមន្តអាគម អ្នកនឹងខ្លាំងពូកែជាងគេក្នុងលោកនេះ ដោយអាចារ្យមានគំនិតថា ក្នុងចំណោម១០០០នាក់ដែលអហឹង្សកុមារសម្លាប់នោះ គង់មានម្នាក់នឹងសម្លាប់វាពុំខាន ។ ដោយពុំដែលបានស្តាប់ធម៌អំពីទោសនៃការសម្លាប់ផង និងដោយគោរពគ្រូផង អហឹង្សកុមារក៏ធ្វើតាមគ្រូប្រាប់ បានសម្លាប់មនុស្សអស់៩៩៩នាក់ យកម្រាមដៃមកដោតចងជាកម្រងព្រោះខ្លាចច្រឡំ ទើបប្រាកដនាមក្នុងពេលនោះថាអង្គុលីមាលចោរ ប្រែថាចោរមានម្រាមដៃជាកម្រងតាំងពីពេលនោះមក ។ ម្តាយរបស់អង្គុលីមាលបានដឹងដំណឹងថា កូនរបស់ខ្លួនប្រព្រឹត្តអំពើឧក្រិដ្ឋដូច្នេះ ក៏ធ្វើដំណើរទៅរកកូន ដើម្បីឃាត់ផងនិងប្រាប់ដំណឹងកូនថា ព្រះបាទបសេនទិកោសលកំពុងលើកទ័ពមកចាប់ផង ។ ព្រះពុទ្ធជាម្ចាស់បានជ្រាប ក៏ប្រញាប់ប្រញាល់យាងទៅប្រោស ដោយព្រះគំនិតថា បើព្រះអង្គពុំយាងទៅប្រោសក្នុងពេលនេះទេ អង្គុលីមាននឹងច្រឡំសម្លាប់ម្តាយឯងទៀត នឹងមានទោសដល់ថ្នាក់អនន្តរិយកម្ម ជាទោសដ៏ធ្ងន់ពិបាកកែ ហើយអង្គុលីមាលនឹងខានបានសំរេចមគ្គផលជាន់ខ្ពស់ ។ ព្រះពុទ្ធបានយាងដំណើរធម្មតា អង្គុលីមាលបានឃើញពុំស្គាល់ថាជាព្រះពុទ្ធទេ ប៉ុន្តែដឹងថាជាអ្នកបួស ក៏ដេញតាមធ្វើឃាត ដោយគិតក្នុងចិត្តថា ធ្វើឃាតមួយនេះទៀតគ្រប់ចំនួន១០០០តាមគ្រូប្រាប់ហើយ។ដោយរត់តាមព្រះពុទ្ធពុំទាន់ក៏ឈប់ហើយស្រែកហៅព្រះពុទ្ធថានែសមណៈឈប់សិន ។ ព្រះពុទ្ធឆ្លើយតបថា នែអង្គុលីមាល ! តថាគតឈប់ហើយ នៅតែអ្នកឯងទេតើដែលមិនទាន់ឈប់ ម្នាលអង្គុលីមាលអ្នកចូរឈប់ចុះ ។ អង្គុលីមាលឆ្ងល់ពាក្យព្រះអង្គដែលពោលនេះ ទើបសួរព្រះអង្គថា នែសមណៈ ! ព្រះអង្គកំពុងយាងតែព្រះអង្គពោលថា តថាគតឈប់ហើយ តើឈប់អ្វី ? ព្រះពុទ្ធឆ្លើយថា តថាគតមានអាវុធដាក់ចុះហើយ ឈប់សម្លាប់អ្នកដទៃហើយ ។ ចុះខ្ញុំព្រះអង្គឈប់នៅស្ងៀម តែព្រះអង្គពោលថា ខ្ញុំព្រះអង្គពុំទាន់ឈប់ តើមានន័យយ៉ាងណា ? ព្រះអង្គតបថា អ្នកឯងមានបាតដៃប្រឡាក់សុទ្ធតែឈាម មានអាវុធក្នុងដៃ ដើរសម្លាប់មនុស្សស្លូតត្រង់គ្មានប្រណី ។ បន្ទាប់ពីបានស្តាប់ការបំភ្លឺរបស់ព្រះពុទ្ធនេះមក អង្គុលីមាលបានយល់ច្បាស់អំពីទោសរបស់ខ្លួនដែលបានសម្លាប់មនុស្ស ដូចគេផ្ងានូវរបស់ដែលផ្កាប់ ឬដូចទីងងឹតដែលគេយកប្រទីបទៅបំភ្លឺ ទើបអង្គុលីមាលដឹងថា នេះជាព្រះពុទ្ធដែលខ្លួនធ្លាប់ឮតែពុំដែលឃើញ រួចទម្លាក់ដាវចុះហើយចូលទៅថ្វាយបង្គំព្រះពុទ្ធដល់ព្រះបាទាហើយពោលថា ខ្ញុំព្រះអង្គបានយល់កំហុសនេះហើយ ព្រះអង្គពិតជាព្រះពុទ្ធរបស់មនុស្សលោក ត្រាស់ដឹងឡើងសំរាប់ស្រោចស្រង់មនុស្សលោក បានបំភ្លឺខ្ញុំព្រះអង្គឲ្យលះបង់អំពើឧក្រិដ្ឋនេះ ។ ពេលនោះ អង្គុលីមាលបានសុំព្រះអង្គទៅវត្តជេតពនហើយសុំបួស ព្រះអង្គក៏អនុញ្ញាតឲ្យបួស ។

ចំណែកព្រះបាទបសេនទិកោសល មុននឹងលើកទ័ពទៅចាប់អង្គុលីមាល បានយាងទៅថ្វាយបង្គំព្រះពុទ្ធដោយព្រះតម្រិះថា បើដំណើរទៅចាប់ចោរនេះមានលក្ខណៈបែបណា ពិតជាព្រះពុទ្ធមានព្រះពុទ្ធដីកាពុំខាន ។ ពេលយាងទៅដល់ ព្រះមហាក្សត្របានក្រាបទូលព្រះពុទ្ធថា ខ្ញុំព្រះអង្គចូលមកមួយអន្លើដោយកងទ័ពនឹងធ្វើដំណើរទៅតាមចាប់ចោរអង្គុលីមាល ដែលអ្នកស្រុកបានឲ្យពត៌មានថា ចោរនេះបានសម្លាប់អ្នកស្រុកអស់ច្រើនណាស់ ។ ពេលនោះព្រះពុទ្ធមានព្រះពុទ្ធដីកាថា បពិត្រមហារាជ ចុះបើចោរអង្គុលីមាលនោះ តថាគតបានបំបួសវិញ តើព្រះសម្មតិទេពមានព្រះតម្រិះដូចម្តេច ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា បើអង្គុលីមាលបួសវិញ ខ្ញុំព្រះអង្គរីករាយណាស់ នឹងឧបត្ថម្ភលោកដោយបច្ច័យ៤ ។ លុះជ្រាបថាអង្គុលីមាលបួសហើយ ព្រះមហាក្សត្របានពោលសរសើរព្រះពុទ្ធថា ព្រះពុទ្ធតែមួយព្រះអង្គឯង គ្មានអាវុធក្នុងព្រះហត្ថ តែអាចបង្ក្រាបចោរដ៏កាចសាហាវបានដោយអាវុធគឺព្រះធម៌ ចំណែកខ្ញុំព្រះអង្គវិញ មានកងទ័ពរហូតដល់៥០០នាក់ មានអាវុធគ្រប់ដៃ ទៅតាមចាប់ចោរដ៏កាចសាហាវនេះពុំបាន ។

អង្គុលីមាលបន្ទាប់ពីបួសហើយបានខំប្រតិបត្តិធម៌ ចំរើនសមថវិបស្សនា មិនយូរប៉ុន្មានក៏បានសំរេចជាព្រះអរហត្តផល ជាព្រះអរហន្តក្នុងសាសនាព្រះពុទ្ធ ។ មូលហេតុដែលនាំឲ្យអង្គុលីមាលបានសំរេចជាព្រះអរហត្ត ហើយបាបដែលសម្លាប់មនុស្សមិនឃើញឲ្យផលមកអំពី ៖

១- ឧបនិស្ស័យរបស់លោកដែលបានកសាងពីអតីតជាតិ ត្រូវបានសំរេចជាព្រះអរហត្តក្នុងបច្ចុប្បន្ននេះ ។

២- អង្គុលីមាលគ្មានមិច្ឆាទិដ្ឋយល់ខុសជុះជាប់ក្នុងសន្តានចិត្តឡើយ ។ ការនាំឲ្យប្រព្រឹត្តខុសមួយពេលដោយការសេពគប់ខុស ។

៣- បានជួបព្រះពុទ្ធជួយណែនាំ ហើយកម្លាំងអរហត្តមានកម្លាំងខ្លាំងក្លាឲ្យផលមុនផុត បាបមិនអាចឲ្យផលបាន ។

កម្មបែបនេះលោកហៅថា អហោសិកម្ម គឺជាអំពើដែលមិនអាចឲ្យផលបាន ដោយសារកម្លាំងអរហត្តផលឲ្យផលមុនផុត។

អហោសិកម្ម គឺកម្មមិនអាចឲ្យផលបាននេះ ជាករណីពិសេសរបស់ព្រះអរិយបុគ្គលខ្លះ ដែលមានឧបនិស្ស័យ ត្រូវបាន សំរេចព្រះអរហត្តផលក្នុងបច្ចុប្បន្នប៉ុណ្ណោះ ។ ចំពោះមនុស្សសត្វទូទៅ ពុំអាចគេចផុតពីកម្មនិងផលរបស់កម្មបានឡើយ សូម្បីព្រះអរហន្តដូចជាព្រះមោគ្គលានត្រូវចោរធ្វើឃាត ដោយអំពើបាបដែលលោកបានធ្វើឃាតមាតានិងបិតារបស់លោកពីអតីតជាតិ គឺលោកនៅតែទទួលផលនោះក្នុងទីបំផុតជាតិ ។៚

☆ ☆

☆